Australian Government

NATIONAL
CERVICAL SCREENING
PROGRAM
A joint Australian, State and Territory Government Program

# ការយល់ដឹងពី លទ្ធផលតេស្តពិនិត្យមាត់ស្បូន របស់អ្នក



## ក្រដាសណែនាំនេះជួយអ្នកឱ្យយល់ដឹងពីលទ្ធផលតេស្តពិនិត្យមាត់ស្បូនរបស់អ្នក។

វេជ្ជបណ្ឌិត ឬគិលានុបដ្ឋាករបស់អ្នកនឹងពិភាក្សាអំពីលទ្ធផលរបស់អ្នក ហើយនិងជំហានបន្តបន្ទាប់ជាមួយអ្នក។

នេះគឺជាពេលវេលាដ៏ល្អមួយដើម្បីសួរសំណួរណាមួយ ឬប្រាប់ពួកគេឱ្យបានដឹងប្រសិនបើអ្នកមានអារម្មណ៍ខ្វល់ខ្វាយអំពីលទ្ធផលរបស់អ្នក។

### តើការធ្វើតេស្តពិនិត្យមាត់ស្បូនរកមើលអ្វីខ្លះ?

ការធ្វើតេស្តពិនិត្យមាត់ស្បូន រកមើលការឆ្លងវីរុស human papillomavirus (HPV)។

វីរុស HPV គឺកើតមានជាទូទៅណាស់ ដោយមនុស្សជាច្រើនមានវានៅក្នុងដំណាក់កាលណាមួយនៃឆាកជីវិតរបស់ពួកគេ ហើយមិនដែលដឹងពីវាទេ ដោយព្រោះជាធម្មតា មិនមានរោគសញ្ញាអ្វីទាំងអស់។

ប៉ុន្តែប្រសិនបើវីរុស HPV ស្ថិតនៅក្នុងខ្លួនយើងអស់រយៈពេលយូរអង្វែង វាអាចបង្កបញ្ហានានាដែលអាចនាំឱ្យកើតជំងឺមហារីកមាត់ស្បូន។ ជាធម្មតាវាត្រូវចំណាយពេលពី 10 ទៅ 15 ឆ្នាំ។

### តើលទ្ធផលតេស្តរបស់ខ្ញុំមានន័យយ៉ាងណាដែរ?

វេជ្ជបណ្ឌិត ឬគិលានុបដ្ឋាករបស់អ្នក នឹងនិយាយជាមួយអ្នកអំពីលទ្ធផលតេស្តពិនិត្យមាត់ស្បូនរបស់អ្នក ហើយនឹងឆ្លើយសំណួរណាមួយដែលអ្នកមាន។

Australian Government

NATIONAL
CERVICAL SCREENING
PROGRAM
A joint Australian, State and Territory Government Program

## ការយល់ដឹងពីលទ្ធផលតេស្តរបស់អ្នក

ទាំងនេះគឺជាលទ្ធផលដែលអាចកើតមាន ហើយថាតើវាមានន័យយ៉ាងណាដែរ។

| | |
|---|---|
| ត្រឡប់ទៅពិនិត្យឡើងវិញក្នុងរយៈពេល 5 ឆ្នាំ | គ្មានវីរុស HPV ត្រូវបានរកឃើញនៅក្នុងសំណាករបស់អ្នកទេ។ ការធ្វើតេស្តបន្ទាប់របស់អ្នកគឺក្នុងរយៈពេល 5 ឆ្នាំក្រោយ។ អ្នកនឹងត្រូវបានគេរំលឹក 3 ខែ មុនពេលដល់កំណត់ការធ្វើតេស្តបន្ទាប់របស់អ្នក។ |
| វិលត្រឡប់ទៅពិនិត្យឡើងវិញដើម្បីយកសំណាកមួយផ្សេងទៀត ដែលប្រមូលដោយអ្នកផ្តល់សេវាកម្មថែទាំសុខភាពរបស់អ្នក។ | អ្នកជ្រើសរើសប្រមូលយកសំណាកដោយខ្លួនឯងសម្រាប់ការធ្វើតេស្តរបស់អ្នក ហើយវីរុស HPV ត្រូវបានរកឃើញនៅក្នុងសំណាកប្រមូលដោយខ្លួនឯងរបស់អ្នក។ អ្នកនឹងត្រូវបានស្នើសុំឱ្យត្រឡប់ទៅជួបវេជ្ជបណ្ឌិត ឬគិលានុបដ្ឋាករបស់អ្នកវិញ។ ពួកគេនឹងប្រមូលសំណាកមួយទៀត ដែលរួមមានកោសិកាមាត់ស្បូន។ អ្នកមិនអាចប្រមូលសំណាកនេះដោយខ្លួនឯងបានទេ។ |
| ធ្វើតេស្តម្តងទៀតក្នុងរយៈពេល 12 ខែក្រោយ | វីរុស HPV ត្រូវបានរកឃើញនៅក្នុងសំណាករបស់អ្នក ប៉ុន្តែរាងកាយរបស់អ្នកប្រហែលជាអាចសម្អាតបំបាត់វាដោយខ្លួនឯងបាន។ វាមានសុវត្ថិភាពទេសម្រាប់អ្នកក្នុងការរង់ចាំ 12 ខែ មុនពេលអ្នកត្រូវធ្វើតេស្តម្តងទៀត។ |
| ធ្វើតេស្តពិនិត្យមាត់ស្បូនម្តងទៀត ព្រោះលទ្ធផលតេស្តមិនច្បាស់លាស់ | មន្ទីរពិសោធន៍មិនអាចសម្រេចបានលទ្ធផលពីសំណាករបស់អ្នកទេ។ នេះមិនមានន័យថា មានអ្វីដំណើរខុសពីធម្មតានោះទេ។ សូមកក់ទុកដើម្បីធ្វើតេស្តរបស់អ្នកម្តងទៀតក្នុងរយៈពេល 6 ទៅ 12 សប្តាហ៍ក្រោយ។ |
| បញ្ជូនបន្តទៅគ្រូពេទ្យឯកទេស | វីរុស HPV ត្រូវបានរកឃើញនៅក្នុងសំណាករបស់អ្នក ហើយប្រភេទនៃការឆ្លងវីរុស HPV ត្រូវការការធ្វើតេស្ត ឬការព្យាបាលបន្ថែមទៀត។ វេជ្ជបណ្ឌិត ឬគិលានុបដ្ឋាករបស់អ្នក នឹងបញ្ជូនបន្តអ្នកទៅគ្រូពេទ្យឯកទេសដើម្បីធ្វើតេស្តមួយផ្សេងទៀត។ |

### ត្រូវការព័ត៌មានបន្ថែមឬ?

ប្រសិនបើអ្នកត្រូវការព័ត៌មានបន្ថែម សូមពិគ្រោះជាមួយវេជ្ជបណ្ឌិត គិលានុបដ្ឋាក ឬបុគ្គលិកថែទាំសុខភាព សូមចូលមើលគេហទំព័រ www.health.gov.au/NCSP ឬទូរសព្ទទៅលេខ **1800 627 701**។

សម្រាប់ជំនួយជាភាសារបស់អ្នក អ្នកអាចទូរសព្ទទៅសេវាកម្មបកប្រែភាសាសរសេរ និងបកប្រែផ្ទាល់មាត់ (TIS National) តាមលេខ **131 450**។ សូមចូលទៅកាន់គេហទំព័រ www.health.gov.au/NCSP-multicultural សម្រាប់ព័ត៌មានដែលបានបកប្រែរួច។